**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

**លេខ** ០១១ សណន

ថ្ងៃ ចន្ទ ៥រោច ខែ ពិសាខ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០២១

# សារាចរណែនាំ

## ស្តីពី

## ការពង្រឹងការអនុវត្តវិធានការនានារបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់អាជីវកម្មសេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍

ទទួលបានការជូនដំណឹងរបស់រដ្ឋបាលរាជធានីភ្នំពេញអំពីការបិទបញ្ចប់បម្រាមគោចរ និងការអនុញ្ញាតគោលការណ៍ពិសេសចំពោះអាជីវកម្មដ្ឋានក្នុង “**តំបន់លឿង**” នៃភូមិសាស្ត្ររាជធានីភ្នំពេញ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ដែលអាជីវកម្មសេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ អាចដំណើរការអាជីវកម្មជាប្រក្រតី និងអាចទទួលអតិថិជនឱ្យចូលមកទទួលទានក្នុងបរិវេណអាជីវកម្មដ្ឋានឡើងវិញ ក្រសួងទេសចរណ៍សូមណែនាំដូចខាងក្រោម៖

១. មន្ទីរទេសចរណ៍រាជធានីភ្នំពេញ ត្រូវសហការជាមួយរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តកណ្តាល និងអាជ្ញាធរមូលដ្ឋាន ជូនដំណឹងអំពីគោលការណ៍អនុញ្ញាតឱ្យបើកដំណើរការប្រតិបត្តិការអាជីវកម្មភោជនីយដ្ឋានជាធម្មតាឡើងវិញនេះ ឱ្យដល់គ្រប់មូលដ្ឋានអាជីវកម្មទាំងអស់។ ជាមួយគ្នានេះ ត្រូវបន្តពិនិត្យ និងពង្រឹងបន្ថែមទៀតនូវការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ និងរាល់វិធានការជាធរមានចំពោះអាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ភោជនីយដ្ឋាននិងអាហារដ្ឋានទេសចរណ៍។

២. មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវបន្តសហការជាមួយរដ្ឋបាលខេត្ត និងអាជ្ញាធរមូលដ្ឋាន ពិនិត្យនិងពង្រឹងបន្ថែមទៀតនូវការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ ចំពោះគ្រប់អាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ភោជនីយដ្ឋាននិងអាហារដ្ឋានទេសចរណ៍។ ដោយឡែកចំពោះមូលដ្ឋានអាជីវកម្មខាងលើដែលស្ថិតនៅក្នុងតំបន់ដែលបានដាក់ចេញវិធានការបិទខ្ទប់ មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវបន្តសហការជាមួយរដ្ឋបាលខេត្ត និងអាជ្ញាធរមូលដ្ឋានបន្តពង្រឹងនូវរាល់វិធានការជាធរមាន។

៣. ត្រូវបន្តពង្រឹងការអនុវត្តឱ្យបានយ៉ាងខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់នូវវិធានការទាំងឡាយដែលបានដាក់ចេញដោយក្រសួងសុខាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍របស់ក្រសួងទេសចរណ៍ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ពិសេសវិធានការ “**៣ការពារ និង ៣កុំ**”។ គ្រប់មូលដ្ឋានអាជីវកម្មខាងលើត្រូវកត់ត្រាអត្តសញ្ញាណ(**ជាពិសេសអាសយដ្ឋាននិងលេខទូរស័ព្ទទំនាក់ទំនង**) ភ្ញៀវទេសចរទាំងអស់។ និងត្រូវចុះឈ្មោះបង្កើត និងប្រើប្រាស់ប្រព័ន្ធ **QR Code “ទប់ស្កាត់កូវីដ-១៩”** និងតម្រូវឱ្យភ្ញៀវទេសចរត្រូវតែស្កេនជាដាច់ខាតមុនចូលទៅក្នុងកន្លែងរបស់ខ្លួន។ ទន្ទឹមនឹងនេះ ត្រូវរៀបចំការត្រួតពិនិត្យកំដៅ ការបាញ់អាល់កុលសម្លាប់មេរោគ និងតម្រូវឱ្យភ្ញៀវទេសចរត្រូវពាក់ម៉ាស (លើកលែងនៅពេលបរិភោគអាហារ និងភេសជ្ជៈ) និងរក្សាគម្លាតសុវត្ថិភាពស្របតាមគោលការណ៍សុខាភិបាល។

៤. មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវបន្តសហការជាមួយរដ្ឋបាលខេត្ត និងអាជ្ញាធរមូលដ្ឋាន ណែនាំបន្តដល់គ្រប់មូលដ្ឋានអាជីវកម្មខាងលើតាមដានត្រួតពិនិត្យរាល់បុគ្គលិករបស់ខ្លួន ដែលកំពុងជាប់កាតព្វកិច្ចធ្វើចត្តាឡីស័ក។ និងតម្រូវឱ្យអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មខាងលើ ត្រូវជូនដំណឹងមកអាជ្ញាធរមូលដ្ឋាននូវរាល់ករណីសង្ស័យចំពោះភ្ញៀវទេសចរដែលជាប់ពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ (**បន្ទាប់ពីស្កេន**

QR Code "**ទប់ស្កាត់កូវីដ-១៩**") និងមិនត្រូវអនុញ្ញាតឱ្យភ្ញៀវទេសចរ និងបងប្អូនប្រជាពលរដ្ឋដែលកំពុងជាប់ធ្វើចត្តាឡីស័ក ឬត្រូវផ្តល់សំណាកធ្វើតេស្តរកជំងឺកូវីដ-១៩ ចូលទៅប្រើប្រាស់សេវាកម្មជាដាច់ខាត។

៥. គ្រប់មូលដ្ឋានអាជីវកម្មខាងលើ ត្រូវពង្រឹងការគ្រប់គ្រងឱ្យបានល្អប្រសើរ ជាពិសេសត្រូវ**កំណត់សមត្ថភាពផ្ទុក (Carrying Capacity)** អតិបរមា ដែលអាចទទួលភ្ញៀវបានក្នុងពេលតែមួយ អនុលោមតាមស្តង់ដាគម្លាតសុវត្ថិភាព និងមិនត្រូវទទួលភ្ញៀវលើសពីចំណុះនេះជាដាច់ខាត។ មិនត្រូវរៀបចំឱ្យមានការជួបជុំជាដាច់ខាត។ ចំពោះការជួបជុំជាក្រុមតូចដែលចាំបាច់(លក្ខណៈជាក្រុមគ្រួសារផ្ទាល់)នៅក្នុងភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ ចាំបាច់ត្រូវតែរក្សាគម្លាតសុវត្ថិភាពបុគ្គលត្រូវមាន**យ៉ាងតិច១,៥០ម៉ែត្រពីគ្នា (មួយម៉ែត្រហាសិបសង់ទីម៉ែត្រ)** និងមានចំនួនកម្រិតអាស្រ័យតាមការកំណត់ដោយឡែករបស់រដ្ឋបាលរាជធានី ខេត្ត។

៦. ព្រមជាមួយវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ គ្រប់មូលដ្ឋានអាជីវកម្មខាងលើត្រូវពង្រឹងគុណភាពសេវាកម្ម ថែរក្សាបរិស្ថាន-អនាម័យ និងរក្សាតម្លៃផលិតផល និងសេវាកម្មឱ្យបានសមរម្យ។

៧. គ្រប់មូលដ្ឋានអាជីវកម្មខាងលើ ត្រូវអនុវត្តសារាចរនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។ ករណីខកខានមិនបានអនុវត្ត ឬអនុវត្តមិនបានត្រឹមត្រូវតាមខ្លឹមសារសារាចរណែនាំនេះ មន្ទីរទេសចរណ៍មិនត្រូវអនុញ្ញាតឱ្យអាជីវកម្មនោះ បើកដំណើរការជាដាច់ខាត និងអាចប្រឈមទៅនឹងវិធានការច្បាប់ជាធរមានពិសេសច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

ទទួលបានសារាចរណែនាំនេះ មន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវសហការជាមួយរដ្ឋបាលរាជធានី ខេត្ត អាជ្ញាធរមូលដ្ឋាន មន្ទីរពាក់ព័ន្ធ និងផ្នែកឯកជន អនុវត្តខ្លឹមសារខាងលើនេះឱ្យមានប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- ខុទ្ទកាល័យ**សម្តេចតេជោនាយករដ្ឋមន្ត្រី**
  "ដើម្បីជូនជ្រាប"
- រដ្ឋបាលរាជធានី-ខេត្ត
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ